# ក្រឹត្យវិន័យមាស

| | |
|---|---|
| **ម៉ាថាយ ៥:៣, នីហ្វៃទី ៣ ១២:៣** | ការមានសេចក្ដីកម្សត់ខាងឯវិញ្ញាណមានន័យថា ការបន្ទាបខ្លួន និង « ការទទួលស្គាល់ដោយដឹងគុណចំពោះការពឹងផ្អែក [ របស់យើង ] លើព្រះអម្ចាស់—យល់ថា [ យើង ] មានសេចក្ដីត្រូវការការផ្គត់ផ្គង់ពីទ្រង់ជាប់ជានិច្ច ។ ការបន្ទាបខ្លួនគឺជាការទទួលស្គាល់ថា ទេពកោសល្យ និង សមត្ថភាព [ របស់យើង ] គឺជាអំណោយទានមកពីព្រះ » ( *ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ ឆ្នាំ ២០០៤ ] ទំព័រ ២៥) ។ |
| **ម៉ាថាយ ៥:៤** | ការយំសោកគឺជាអារម្មណ៍ ឬការបង្ហាញអារម្មណ៍សោកសៅ ។ មនុស្សម្នាក់អាចយំសោកដោយសារការលំបាក និង ការសាកល្បងនៃជីវិតរមែងស្លាប់ រួមទាំងសេចក្ដីស្លាប់នៃមនុស្សជាទីស្រឡាញ់ផងដែរ ។ ដូចគ្នានេះដែរ មនុស្សម្នាក់ក៏អាចយំសោកដោយសារតែភាពសោកសៅនៃអំពើបាប ។ |
| **ម៉ាថាយ ៥:៥** | « “ភាពស្លូតត្រង់ ដូចដែលបានឲ្យនិយមន័យនៅក្នុងវចនានុក្រម Webster គឺជា ‹ ការបង្ហាញភាពអត់ធ្មត់ និង ការអត់ទ្រាំដ៏យូរ ដោយស៊ូទ្រាំរងរបួសដោយគ្មានការសោកស្ដាយ › [*Webster’s Third New International Dictionary* ( ឆ្នាំ១៩៧៦ ) ‹ meek › ទំព័រ ១៤០៣ ] ។ ភាពស្លូតត្រង់ពុំមែនជាភាពទន់ខ្សោយនោះទេ ។ វាគឺជាស្លាកឈ្មោះនៃភាពក្លាហានរបស់ពួកគ្រីស្ទាន » ( រ៉ូបឺត ឌី ហែល « Christian Courage:  The Price of Discipleship », *Ensign* ឬ *Liahona* ខែវិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៧៣ ) ។ |
| **ម៉ាថាយ ៥:៦, នីហ្វៃទី ៣ ១២:៦** | ការស្រេកឃ្លាននូវសេចក្ដីសុចរិតបញ្ជាក់ពីបំណងប្រាថ្នាដ៏ធំធេងមួយដើម្បីដឹង ហើយធ្វើតាមព្រះទ័យនៃព្រះ ។ |
| **ម៉ាថាយ ៥:៧** | « ចិត្តមេត្តាករុណា គឺជាការព្យាបាលមនុស្សម្នាក់ដោយចិត្តអាណិតអាសូរលើសពីអ្វីដែលបុគ្គលនោះសមនឹងទទួលបាន » (« Mercy » Gospel Topics lds.org/topics ) ។ យើងអាចទទួលបានសេចក្ដីមេត្តាករុណាពីព្រះវរបិតាសួគ៌ដោយសារតែដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ( សូមមើល អាលម៉ា ៣៣:១១ ) ។ |
| **ម៉ាថាយ ៥:៨** | « អ្នកដែលមានចិត្តបរិសុទ្ធគឺជាជនដែលស្រឡាញ់ព្រះអម្ចាស់ ខិតខំធ្វើតាមទ្រង់ ហើយគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ជាជនដែលកំពុងព្យាយាមរស់នៅក្នុងជីវិតប្រកបដោយគុណធម៌ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុតដោយស្មោះត្រង់ ។ អ្នកដែលមានចិត្តបរិសុទ្ធគឺជាជនដែលគ្រប់គ្រងគំនិតខ្លួន ដើម្បីធ្វើឲ្យខ្លួនឯងមានសេរីភាពពីចំណង់ប្លែកៗ និងទង្វើអសីលធម៌នានា » ( សែលដុន អែហ្វ ឆាល « Words of Jesus: Chastity » *Ensign* ខែមករា ឆ្នាំ ២០០៣ ទំព័រ ៤៤ ) ។ |
| **ម៉ាថាយ ៥:៩** | « [ ការផ្សះផ្សា ] គឺជាអំណោយទានដើម្បីជួយមនុស្ស ឲ្យរកឃើញចំណុចរួម ពេលមនុស្សដទៃទៀតកំពុងមើលឃើញពីភាពខុសគ្នា » ( ហិនរី ប៊ី អាវរិង « Learning in the Priesthood » *Ensign* ឬ *Liahona* ខែឧសភា ឆ្នាំ ២០១១ ទំព័រ ៦៣ ) ។ |
| **ម៉ាថាយ ៥:១០–១២** | ការត្រូវបានគេ « បៀតបៀនដោយព្រោះសេចក្ដីសុចរិត » មានន័យថា ការយល់ព្រមគោរពតាម ហើយការពារព្រះយេស៊ូវគ្រីស្ទ និងការបង្រៀនរបស់ទ្រង់ សូម្បីតែពេលយើងត្រូវបានគេសើចចំអកឲ្យ ឬធ្វើបាបដោយសារតែការធ្វើដូច្នោះក្ដី ។ |



© ឆ្នាំ២០១៥ ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង ។